# មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# (១៩៧៥–១៩៧៩)

## ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## រវាងគ្រូ សិស្ស និងឪពុកម្តាយ

**ភូមិកំពង់បឹង ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង**

**ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១០**



*ភូមិ និងវត្តលិចទឹកក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង*

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១០ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រារព្ធធ្វើវេទិកាអប់រំសាធារណៈមួយនៅក្នុងឃុំកំពង់បឹង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ មានសិក្ខាកាមចូលរួមចំនួនប្រហែល២០០នាក់ ក្នុងនោះមានប្រជាជនចំនួន២៨នាក់ គ្រូចំនួន១៨នាក់ ព្រះសង្ឃចំនួន១៤អង្គ និងក្រៅពីនេះ គឺជាសិស្សានុសិស្សមកពីវិទ្យាល័យហ៊ុន សែន កំពង់លែង ។ វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងអស់រយៈពេលជិតបី

ម៉ោង ដែលបានចាប់ផ្ដើមពីម៉ោង៨ៈ៣០នាទីព្រឹក ហើយបានបញ្ចប់នៅម៉ោង១១ៈ៣០នាទីព្រឹកនៅក្នុងព្រះវិហារវត្តអម្ពវនារាម ដែលមានទីតាំងស្ថិតនៅក្នុងទីរួមស្រុកកំពង់លែង ។

វេទិកានេះបានចាប់ផ្ដើម ដោយមានការណែនាំពីលោក ផេង ពង្សរ៉ាស៊ី អំពីគោលបំណងនៃការធ្វើវេទិកាសាធារណៈនិងការបំពេញ "តារាងស្ទាបស្ទង់មតិមុនពេលបើកវេទិកាសាធារណៈ" ដើម្បីវាស់ស្ទង់ការយល់ដឹងរបស់អ្នកចូលរួម និងការចាប់អារម្មណ៍នៅក្នុងការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ។ បន្ទាប់មក តំណាងក្រុមប្រឹក្សាឃុំបានផ្ដល់ការស្វាគមន៍ក្នុងការបើកវេទិកានេះ និងលើកទឹកចិត្តដល់អ្នកចូលរួមទាំងអស់ឲ្យយកចិត្តទុកដាក់រៀនសូត្រពីវេទិកាលើកនេះ ។ បន្ទាប់មក កញ្ញា លី សុខចំរើន ដែលជាសមាជិកនៅក្នុងគម្រោងស្ដីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាអ្នកឡើងធ្វើបទបង្ហាញជំពូក៩(មន្ទីរស-២១ ឬគុកទួលស្លែង) នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានលើកជាសំណួរ និងចម្លើយផង ។ នៅចុងបញ្ចប់នៃវេទិកាសាធារណៈ "តារាងស្ទាបស្ទង់មតិក្រោយវេទិកាសាធារណៈ" ត្រូវបានចែកជូនដល់អ្នកចូលរួមទាំងអស់ ដើម្បីបំពេញពីកម្រិតនៃការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្ទាប់ពីបានចូលរួមនៅក្នុងវេទិកានេះរួចមក ។ នៅពេលរសៀល សមាជិកក្រុមទាំងអស់បានធ្វើសម្ភាសន៍ជាមួយអ្នកចូលរួមចំនួន១២រូប ក្នុងនោះមាន៣រូបជាឪពុកម្ដាយរបស់សិស្ស ២រូបជាគ្រូបង្រៀន និង៧រូបជាសិស្ស ។

## លក្ខណៈភូមិសាស្ត្រ

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ គឺមុនមួយថ្ងៃនៃការធ្វើវេទិកាសាធារណៈ ក្រុមការងារបានធ្វើដំណើរចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាឆ្ពោះទៅកាន់ខេត្តកំពង់ឆ្នាំង ។ នៅវេលាម៉ោង១១ៈ៣០នាទីព្រឹក ក្រុមការងារបានធ្វើដំណើរមកដល់ទីរួមខេត្តកំពង់ឆ្នាំង និងបានធ្វើដំណើរបន្តទៅកាន់ស្រុកកំពង់លែងតាមកាណូតឆ្លងកាត់ទន្លេសាប ដែលមានចម្ងាយប្រមាណ១៣គីឡូម៉ែត្រពីទីរួមខេត្តកំពង់ឆ្នាំង ។ ដោយសាររដូវនេះជារដូវទឹកតំឡើង ផ្ទះរបស់ប្រជាជនមួយចំនួនក្នុងភូមិពោធិ៍អណ្ដែត រួមទាំងវត្តពោធិ៍អណ្ដែតផង ត្រូវលិចទឹក ។ ដូច្នេះទាំងការរស់នៅរបស់អ្នកស្រុក និងការធ្វើបុណ្យទាន គឺត្រូវស្ថិតនៅក្នុងទឹក ។ ទោះជាយ៉ាងដូច្នេះក៏ដោយប្រជាជនដែលរស់នៅទីនោះ បានប្រើប្រាស់ទឹកតំឡើងនេះ សម្រាប់ស្រោចស្រប់ដំណាំស្រូវ និងខ្លះទៀតប្រកបរបរនេសាទត្រី ។

នៅពេលដែលក្រុមការងារបានទៅដល់ទីតាំងសម្រាប់ការប្រារព្ធធ្វើវេទិកាសាធារណៈនៅក្នុងភូមិកំពង់បឹង យើងបានជួបនិងពិភាក្សាជាមួយលោកស្រី វ៉ាន់ធន ជាប្រធានក្រុមប្រឹក្សាឃុំ និងលោក សេង លីរតនៈជាគ្រូបង្គោលថ្នាក់ខេត្ត ។ អ្នកទាំងពីរបានជួយយើងក្នុងការរៀបចំធ្វើវេទិកាសាធារណៈ និងការអញ្ជើញប្រជាជន គ្រូបង្រៀន និងសិស្សានុសិស្សឲ្យចូលរួមក្នុងវេទិកានេះ ។ នៅថ្ងៃដដែលនោះ យើងបានផ្ញើឯកសារសៀវភៅ និងឧបករណ៍ប្រើប្រាស់ផ្សេងៗដែលបម្រើឲ្យការធ្វើវេទិកា នៅនឹងផ្ទះលោកស្រីប្រធានក្រុម

*ប្រឹក្សាឃុំ ពីព្រោះផ្ទះរបស់គាត់ស្ថិតនៅជិតវត្តអម្ពវ័នារាមដែលជាកន្លែងប្រារព្ធពិធីនៅថ្ងៃស្អែក ។ ឆ្លៀតក្នុងឱកាសនោះ យើងបានធ្វើការពិភាក្សាជាមួយលោកស្រី វ៉ាន់ធន អំពីព័ត៌មានទូទៅនៅក្នុងឃុំកំពង់ហៅ និងបទពិសោធន៍របស់គាត់ឆ្លងកាត់របបខ្មែរក្រហម ។*

*ក្រោយការពិភាក្សា យើងបានដឹងថា លោកស្រី វ៉ាន់ធន បានធ្វើជាប្រធានក្រុមប្រឹក្សាឃុំអស់រយៈពេលពីរអាណត្តិទាំងអាណត្តិនេះ ។ គាត់រស់នៅតែម្នាក់ឯងនៅក្នុងផ្ទះតូចល្មមមួយដែលប្រកបទៅដោយក្ដីសុខ ។ គាត់មានស្រុកកំណើតនៅក្នុងភូមិកំពង់បឹងនិងបានរស់នៅទីនេះរហូតមក ។ បន្ទាប់ពីបានរៀបការជាមួយទាហានម្នាក់ លោកស្រីនិងស្វាមីបានផ្លាស់ប្ដូរទៅរស់នៅទីក្រុងភ្នំពេញ ។ នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកស្រី ព្រមទាំងក្រុមគ្រួសារ ត្រូវបានជម្លៀសឲ្យត្រឡប់មកកាន់ស្រុកកំណើតវិញ ។ គាត់បានចំណាយពេលអស់១០ថ្ងៃក្នុងការធ្វើដំណើរត្រឡប់មកផ្ទះរបស់គាត់ ។ គាត់មានការលំបាកខ្លាំងណាស់ក្នុងការនាំយកកូនពីរនាក់ និងបង្វិចខោអាវរបស់គាត់ត្រឡប់មកវិញ ។ បន្ទាប់ពីមកដល់ភូមិស្រុកវិញ ប្ដីរបស់គាត់ត្រូវបាននាំចេញទៅនិងសម្លាប់ ។ ក្រោយមកទៀត កូនរបស់គាត់ទាំងពីរនាក់បានស្លាប់ដោយអត់អាហារ ។ គាត់ត្រូវបានផ្លាស់ប្ដូរទៅកាន់ឃុំស្វាយរំពារ ដើម្បីស្ទូងស្រូវ និងលើកទំនប់អូរតាប៉ិន ។ អូរតាប៉ិន គឺជាអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហមនៅក្នុងស្រុកកំពង់លែង[១] ។ គាត់បាននិយាយថា សមាជិកគ្រួសាររបស់គាត់ចំនួន៣៨នាក់បានស្លាប់ក្នុងរបបខ្មែរក្រហម ។ អ្នកទាំងនោះគឺ ប្ដី កូន ឪពុកម្ដាយ បងប្អូន ជីដូនជីតា អ៊ំស្រី បងប្អូនជីដូនមួយ និងបងប្អូនសាច់ឆ្ងាយជាច្រើននាក់ទៀត ។ លោកស្រី វ៉ាន់ធន បាននិយាយថា នៅឆ្នាំ១៩៧៩ គាត់ស្ទើរក្លាយខ្លួនជាមនុស្សវិកលចរិក ដោយសារតែសមាជិកគ្រួសាររបស់គាត់ទាំងអស់បានស្លាប់ ។ គាត់មានការតូចចិត្ត នៅពេលដែលគាត់បានឃើញសមាជិកគ្រួសារផ្សេងទៀតបានវិលត្រឡប់មកស្រុកកំណើតវិញទាំងអស់គ្នា ។ លោកស្រី វ៉ាន់ធន បានប្រាប់ថា បទពិសោធន៍ឈឺចាប់របស់គាត់ហាក់ដូចជានៅថ្មីៗនិងស្ថិតនៅជារៀងរាល់ថ្ងៃ ។ គាត់យំគ្រប់ពេល នៅពេលដែលគាត់រំឭកឡើងវិញពីការឈឺចាប់ និងការចងចាំទាំងនោះ ។*

*យោងតាមការពិភាក្សាជាមួយលោកស្រី វ៉ាន់ធន និងអ្នកភូមិផ្សេងទៀត យើងបានដឹងថា ស្រុកកំពង់លែង គឺជាទីតាំងសមរភូមិដ៏សំខាន់មួយរវាងខ្មែរក្រហម និងរដ្ឋាភិបាលលន់ នល់ កាលពីមុនឆ្នាំ១៩៧៥ ។ នៅក្រោយឆ្នាំ១៩៧៩ ស្រុកនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រហូតដល់ឆ្នាំ១៩៩៨ ទាហានខ្មែរក្រហមនៅតែបន្តការបំភិតបំភ័យ សម្លាប់ និងឆក់ប្លន់អ្នកភូមិដែលរស់នៅក្នុងស្រុកនេះ ។ ជាការពិត ទាហានខ្មែរក្រហមបានចាប់ខ្លួនលោកស្រី វ៉ាន់ធន នៅឆ្នាំ១៩៩៨ ពីបទបានផ្សព្*

---

[១] *របាយការណ៍របស់ក្រុមស្រាវជ្រាវធ្វើផែនទីរណ្ដៅសាកសព បានបង្ហាញថាអូរតាប៉ិនគឺជាឈ្មោះរបស់មន្ទីរសន្តិសុខរបស់ខ្មែរក្រហម ដែលមានទីតាំងស្ថិតនៅក្នុងឃុំស្វាយរំពារ ស្រុកកំពង់លែង ដែលប្រជាជនជាច្រើននាក់ត្រូវបានសម្លាប់ ។*

ផ្សាយព័ត៌មានអំពីការងាររបស់គាត់នៅក្នុងសមាគមន៍ស្ត្រីស្រុក ។ គាត់ត្រូវបានដោះលែងមកវិញ នៅល្ងាចថ្ងៃដដែល បន្ទាប់ពីគាត់បានសន្យាថានឹងឈប់បម្រើការងារឲ្យរដ្ឋាភិបាលនេះតទៅទៀត ។ ស្រុកកំពង់លែង គឺជាស្រុកមួយដែលពោរពេញទៅដោយតំបន់អសន្តិសុខនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៩ ។

វត្តអម្ពវនារាម ជាកន្លែងដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជ្រើសរើសយកធ្វើជាកន្លែងប្រារព្ធធ្វើវេទិកាសាធារណៈ ។ វត្តនេះ គឺជាវត្តមួយក្នុងចំណោមវត្តដែលមានវ័យចំណាស់ជាងគេចំនួនពីរក្នុងស្រុកកំពង់លែង មានទីតាំងដំបូងស្ថិតនៅជាប់ជើងភ្នំមួយក្នុងភូមិខ្វែងពណ៌ ឃុំត្រងិល ដែលកាលនេះវត្តនេះមានឈ្មោះថា "វត្តក្រោម" ។ ចំណែកវត្តមួយផ្សេងទៀត គឺស្ថិតនៅលើកំពូលភ្នំ មានឈ្មោះថា "វត្តភ្នំ" ដែលបច្ចុប្បន្ននេះបានកែឈ្មោះទៅជា"វត្តគិរីរស្មី" វិញ ។ ដោយសារវត្តទាំងពីរនេះស្ថិតនៅជិតគ្នា ព្រះចៅអធិការវត្តក្រោម បានសម្រេចចិត្តប្តូរទីតាំងទៅកាន់ភូមិកំពង់បឹងវិញ ហើយមានទីតាំងរហូតមកដល់បច្ចុប្បន្ននេះ ។ ការសាងសង់វត្តនេះ បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៤៨ ដោយបានប្តូរឈ្មោះទៅជា "វត្តថ្មី ឬវត្តពោធិ៍ត្រៃយ៍" ។ សម្តេចព្រះសង្ឃរាជ ជួន ណាត បានធ្វើជាគណអធិបតីនៅក្នុងពិធីសម្ពោធ និងបានផ្តល់ឈ្មោះថ្មីថា "វត្តអម្ពវនារាម" ដែលមានន័យថា ដើមស្វាយ ។ វត្តនេះត្រូវបានប្រើប្រាស់ធ្វើជាឃ្លាំងសេដ្ឋកិច្ចប្រចាំស្រុកកំពង់លែងក្នុងរបបខ្មែរក្រហម ។ សំណង់អគារវត្តនេះ បានស្ថិតនៅរហូតមកដល់បច្ចុប្បន្ន ប៉ុន្តែរូបព្រះបដិមាក្នុងព្រះវិហារត្រូវបានបំផ្លាញចោលគ្មានសល់ ។ កងចល័ត និងទាហានរបស់ខ្មែរក្រហម បានស្នាក់នៅក្នុងវត្តនេះ ដែលព្រះវិហារមានបីជាន់ ។ ជាន់ក្រោមនៃព្រះវិហារ ត្រូវបានប្រើប្រាស់ធ្វើជាម៉ាស៊ីនកិនស្រូវ ។ ជាន់ទីមួយ គឺជាឃ្លាំងដាក់សម្ភារៈសម្រាប់ធ្វើស្រែនិងសម្ភារៈផ្សេងៗទៀត ហើយជាន់ទីពីរគឺជាកន្លែងប្រជុំ ។ លើសពីនេះទៀត អនុវិទ្យាល័យដែលមានទីតាំងនៅក្បែរនោះ គឺត្រូវបានខ្មែរក្រហមប្រើប្រាស់ធ្វើជាឃ្លាំងដាក់អំបិល ។ បន្ទាប់ពីឆ្នាំ១៩៧៩ វត្តនេះត្រូវបានរៀបចំមុនគេនៅក្នុងស្រុកកំពង់លែង ។ ប្រជាជនបានចាប់ផ្តើមសំអាត ជួសជុលអគារ និងប្រណិបត្តិសាសនាតាមប្រពៃណីទំនៀមទម្លាប់ឡើងវិញ ។ ចំណែកវត្តដែលមានទីតាំងនៅក្បែរនេះ ត្រូវខ្មែរក្រហមបំផ្លាញ ហើយដែកដែលបានក្រោយការបំផ្លាញនេះ ត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់ស្ពាន និងទំនប់របស់ខ្មែរក្រហម ។

## កម្មវិធីនៃការធ្វើវេទិកាសាធារណៈ

### ១) បើកកម្មវិធី

លោក ផេង ពង្សរ៉ាស៊ី បានបើកកម្មវិធីសម្រាប់ការធ្វើវេទិកាសាធារណៈ ដោយបានពន្យល់ពីគោលបំណងនៃធ្វើវេទិកាសាធារណៈដល់អ្នកចូលរួម ។ រ៉ាស៊ី បានពន្យល់ថា វេទិកានេះមានបំណងបង្កើតឲ្យមានការពិភាក្សានៅក្នុងក្រុមគ្រួសារ និងសហគមន៍នៅតាមទីជនបទឆ្ងាយៗក្នុងប្រទេសកម្ពុជា ដែលការចែកចាយសៀវភៅប្រវត្តិកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការសិក្សាអំពីរបបនេះនៅមានកម្រិតនៅ

ឡើយ ។ វ៉ាស៊ី បានបញ្ជាក់ថា ក្មេងជំនាន់ក្រោយគួរស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការសួរនាំឪពុកម្តាយរបស់ខ្លួន និងអ្នកចាស់ទុំនៅក្នុងភូមិដែលគាត់កំពុងតែមានវត្តមាននៅក្នុងវេទិកានេះស្រាប់ ។ នៅពេលដែល វ៉ាស៊ី សួរសិស្សអំពីការសិក្សាប្រវត្តិខ្មែរក្រហមនៅក្នុងថ្នាក់រៀន សិស្សទាំងអស់ឆ្លើយថា «មិនធ្លាប់បានរៀន» ។ ចម្លើយនេះអាចបញ្ជាក់បានពីកម្រិតនៃការយល់ដឹងអំពីមាតិការនៃប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាសង្គម ។ វ៉ាស៊ី ក៏បាននិយាយដែរអំពីការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យថា សៀវភៅចំនួន៣០០.០០០ក្បាលបានត្រូវចែកទៅដល់គ្រប់អនុវិទ្យាល័យ និងវិទ្យាល័យនៅក្នុងទូទាំងប្រទេសកម្ពុជា នៅពេលដែលសៀវភៅនេះចំនួន៧០០.០០០ក្បាលទៀត កំពុងត្រូវបានបោះពុម្ពនៅឡើយ ។ សៀវភៅទាំងនេះ នឹងត្រូវធ្វើការចែកចាយនៅក្នុងអំឡុងឆ្នាំក្រោយទៀត ។ វ៉ាស៊ី បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបណ្តុះបណ្តាលគ្រូបង្រៀនរាប់ពាន់នាក់អំពីវិធីសាស្ត្រក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

ឆ្លៀតក្នុងឱកាសនេះដែរ វ៉ាស៊ី ក៏បាននិយាយអំពីគោលបំណងនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប្រាប់ដល់អ្នកចូលរួមទាំងអស់ ។ វ៉ាស៊ី បានចាប់ផ្តើមដូច្នេះថា ការបង្រៀនពីប្រវត្តិសាស្ត្រនឹងជួយតម្រង់ផ្លូវដល់កូនចៅជំនាន់ក្រោយមិនឲ្យមានការគុំគួននិងស្អប់ខ្ពើមគ្នា ប៉ុន្តែគឺជួយឲ្យមានការលើកកម្ពស់ដល់ការផ្សះផ្សាជាតិ និងការកសាងសន្តិភាពនៅក្នុងសង្គមកម្ពុជាទាំងមូល ។

កម្មវិធីបន្ទាប់មកទៀត លោក ខេង សុខាន ជាតំណាងក្រុមប្រឹក្សាឃុំ បានថ្លែងទៅកាន់អ្នកចូលរួមអំពីការបើកអង្គវេទិកាសាធារណៈនេះជាផ្លូវការ ។ លោក សុខាន បានប្រាប់ពីការចាប់អារម្មណ៍ និងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការបើកវេទិកានេះ ។ គាត់បានហៅការបើកវេទិកានេះ ថាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់ភូមិរបស់គាត់ ដើម្បីផ្តល់ការពិភាក្សាអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមដែលបានកើតឡើងអស់រយៈពេលជាង៣០ឆ្នាំកន្លងមក ។ បន្ទាប់មក គាត់បាននិយាយពីបទពិសោធន៍របស់គាត់ឆ្លងកាត់របបខ្មែរក្រហម និងបានសំដែងពីការភ្ញាក់ផ្អើលនៅពេលដែលគាត់បើកសៀវភៅអាន និងឃើញពីការកសាងទំនប់និងមន្ទីរសន្តិសុខ ស-២១ ។ គាត់ក៏បានបន្ថែមទៀតថា គាត់គឺជាអតីតកម្មាភិបាលខ្មែរក្រហមដែលធ្លាប់បម្រើការនៅក្នុងកងសេដ្ឋកិច្ចស្រុក និងធ្លាប់បានស្នាក់នៅក្នុងវត្តនេះ ។ សុខាន បានថ្លែងថាកម្មាភិបាលខ្មែរក្រហមបានបំផ្លាញរូបបដិមានៅក្នុងព្រះវិហារ ហើយព្រះសង្ឃទាំងអស់ត្រូវបានផ្សឹក និងបង្ខំឲ្យធ្វើការជាទម្ងន់ ។

បន្ទាប់ពីការថ្លែងបើកអង្គវេទិកាសាធារណៈ វ៉ាស៊ី បានសង្ខេបឡើងវិញនូវអ្វីដែលលោកតំណាងក្រុមប្រឹក្សាឃុំបាននិយាយអំពីជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម ។ វ៉ាស៊ី បានប្រាប់ទៅសិស្សានុសិស្សទាំងអស់ឲ្យអានជំពូក៧នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើចង់ដឹងអំពីការឈឺចាប់ដែលប្រជាជនកម្ពុជាជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។ បន្ទាប់មក ក្រុមការងារបានចែក «តារាងស្ទាបស្ទង់មតិមុនការធ្វើវេទិកាសាធារណៈ» ដល់អ្នកចូលរួមទាំងអស់ឲ្យបំពេញក្នុងរយៈពេល១៥នាទី ហើយក្នុងពេលជាមួយ

គ្នានេះដែរ ក្រុមការងារបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់អ្នកចូលរួមទាំងអស់ ដើម្បីត្រៀមចាំសកម្មភាពបន្ទាប់ទៀត ។

វ៉ាស៊ី បានណែនាំកញ្ញា លី សុខចំរើន ឲ្យធ្វើបទបង្ហាញជំពូក៩នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់អ្នកចូលរួមទាំងអស់ ។ វ៉ាស៊ី ក៏បានលើកទឹកចិត្តសិស្សានុសិស្ស អ្នកភូមិ និងលោកគ្រូអ្នកគ្រូទាំងអស់ឲ្យសួរសំណួរឲ្យបានច្រើនទៅកាន់ ចំរើន និងលោក ឌី ខាំបូលី ដែលជាអ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ វ៉ាស៊ី ក៏បានស្នើសុំឲ្យអ្នកភូមិដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហមជួយឆ្លើយសំណួរដែលជាចម្ងល់របស់សិស្សានុសិស្ស ដើម្បីបង្ហាញពីការពិភាក្សាគ្នារវាងក្មេងជំនាន់ក្រោយជាមួយនឹងមនុស្សវ័យចំណាស់ ។

## ២) ការធ្វើបទបង្ហាញពីជំពូក៩ ៖ មន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង) ដោយ លី សុខចំរើន

មុនពេលដែល ចំរើន ចាប់ផ្តើមធ្វើបទបង្ហាញ លោក ឌី ខាំបូលី បានធ្វើសេចក្តីសង្ខេបខ្លីមួយពីមាតិកានៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់អ្នកចូលរួម ដើម្បីចែករំលែកពីទស្សនៈនៃប្រវត្តិសាស្ត្រខ្មែរក្រហម មុនពេលដែលអ្នកចូលរួមទាំងអស់មើលទៅលើជំពូក៩នៃសៀវភៅនេះ ។ បូលី បានសួរសិស្សពីការធ្លាប់ឃើញនិងអានសៀវភៅនេះពីមុនមកដែរឬទេ ។ សិស្សខ្លះបានលើកដៃ និងបានឆ្លើយតបវិញថា ខ្លួនធ្លាប់បានអានសៀវភៅនេះនៅក្នុងបណ្ណាល័យនៅក្នុងសាលា ។ បូលី បានប្រាប់អ្នកចូលរួមទាំងអស់ថា សៀវភៅនេះមាន១១ជំពូក ដែលអធិប្បាយពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម ជីវិតរស់នៅក្រោមរបបខ្មែរក្រហម និងការដួលរលំរបស់ខ្មែរក្រហម ។ បូលី បានបន្តថា ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមអាចកើតឡើងនៅទីកន្លែង និងពេលវេលាខុសៗគ្នា មិនចាំបាច់ត្រូវតែរៀននៅក្នុងថ្នាក់រៀន ដែលបង្រៀនដោយគ្រូនោះទេ ។ សិស្សានុសិស្សអាចរៀនពីឪពុកម្តាយ និងជីដូនជីតារបស់ខ្លួន ព្រមទាំងនរណាម្នាក់ដែលនៅរស់រានមានជីវិតក្រោយរបបខ្មែរក្រហម ។ បូលី បានចង្អុលបង្ហាញព្រះតេជគុណ អ៊ុល ប៊ុន ជាឧទាហរណ៍ថា ព្រះតេជគុណមានព្រះជន្មាយុ៧៦ព្រះវស្សានិងធ្លាប់បានរស់នៅឆ្លងកាត់ជាច្រើនជំនាន់តាំងពីជំនាន់ឥស្សរៈ ។ ព្រះតេជគុណគួរតែជាមនុស្សម្នាក់ដែលមានចំណេះដឹង រឿងរ៉ាវ និងបទពិសោធន៍ច្រើនអនេក ដើម្បីចែករំលែកដល់សិស្សានុសិស្សទាំងអស់ ។

បូលី បានប្រាប់អ្នកចូលរួមទាំងអស់ឲ្យបើកសៀវភៅត្រង់ទំព័រទី៥៩ ដែលសរសេរអំពីគុកទួលស្លែង ។ បូលី ចង់ដឹងថាតើមានសិស្សានុសិស្សប៉ុន្មាននាក់ចង់ដឹងឲ្យកាន់តែច្បាស់ថែមទៀតអំពីគុកទួលស្លែង និងនរណាខ្លះដែលបានទៅទស្សនាគុកទួលស្លែងនាពេលកន្លងមក ។ ស្ត្រីម្នាក់បានលើកដៃឡើង ។ បូលី បានអញ្ជើញគាត់ឲ្យឡើងនិយាយពីការទស្សនានេះប្រាប់ដល់អ្នកចូលរួមទាំងអស់ ។ ស្ត្រីនោះបានរៀបរាប់ដូចខាងក្រោម៖

> *ខ្ញុំបានទៅទស្សនាគុកទួលស្លែងនៅឆ្នាំ១៩៧៩ ។ រដ្ឋាភិបាលបានបើកទ្វារគុកទួលស្លែងសម្រាប់បង្ហាញដល់ទស្សនិកជន ចូលទស្សនាពីរឿងរ៉ាវពិតដ៏គួរឲ្យរន្ធត់ដែលបានកើតឡើងនៅ*

គុកទួលស្លែង ។ ខ្ញុំបានឃើញកន្លែងដែលពួកគេ(ខ្មែរក្រហម)ដកក្រចកអ្នកទោស និងកន្លែងដែលពួកគេរុញក្បាលអ្នកទោសបញ្ចូលក្នុងពាងទឹក ។ អ្នកទោសត្រូវបានដាក់ឲ្យសត្វខាំ និងបង្ករឈាម ។ អ្នកទោសត្រូវបានដាក់ក្នុងបន្ទប់តូចៗ ។ លលាដ៏ក្បាលត្រូវបានដឹកចេញពីរណ្តៅ និងដាក់គរនៅនឹងមាត់រណ្តៅដែលស្ថិតនៅក្បែរគុក ។ នៅក្នុងបន្ទប់តូចៗ អ្នកទោសមិនអាចរើខ្លួនបានឡើយ ហើយអ្នកទាំងនោះត្រូវបត់ជើងធំនៅក្នុងកេះគ្រាប់តូចៗ ។ បន្ទប់តូចៗទាំងនេះ មើលទៅហាក់ដូចជាក្ការមឈូស ។ ដើរកាត់តាមបរិវេណគុក ខ្ញុំមានអារម្មណ៍ភ័យខ្លាច និងគិតពីបទពិសោធន៍របស់ខ្ញុំកាលពីក្នុងរបបខ្មែរក្រហម ។ សាស្ត្រាចារ្យ និងអ្នកធ្វើការត្រូវបានចាប់ដាក់ឃុំឃាំង និងសម្លាប់នៅទីនោះ ។ អ្នកទោសត្រូវបានបង់លេខរៀងដោយដាក់ព្យួរនៅនឹងករបស់ខ្លួន ។ កម្មាភិបាលខ្មែរក្រហមបានថតរូបអ្នកទោស ហើយបន្ទាប់មកអ្នកទោសទាំងនោះបានស្លាប់ ។ អ្នកទស្សនាបានស្រែកយំ នៅពេលដែលគាត់បានឃើញរូបថតសាច់ញាតិរបស់ខ្លួន ។ បន្ទប់មួយចំនួនត្រូវបានប្រើប្រាស់សម្រាប់ធ្វើទារុណកម្ម ។

បន្ទាប់ពីការរៀបរាប់ពីការចូលទស្សនាគុកទួលស្លែងរបស់អ៊ីស្រ៊ីរួចមក កញ្ញា លី សុខចំរើន បានចាប់ផ្តើមបង្រៀនជំពូក៩នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ មុនពេលចាប់ផ្តើមបង្រៀន ចំរើន បានពិនិត្យមើលថា តើអ្នកចូលរួមទាំងអស់មានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅនឹងដៃគ្រប់គ្នាហើយឬនៅ ។ បន្ទាប់មក ចំរើន បានបែងចែកអ្នកចូលរួមទាំងអស់ជា៦ក្រុមតូចៗ ដើម្បីទទួលខុសត្រូវក្នុងការអាន៦ចំណុចផ្សេងគ្នានៅក្នុងជំពូក៩ ។

- ក្រុមទី១ : អាន និងពិភាក្សាអំពី “អគារនៃមន្ទីរស-២១” នៅទំព័រទី៦០ ។
- ក្រុមទី២ : អាន និងពិភាក្សាអំពី “អ្នកទោស” នៅទំព័រទី៦០-៦១ ។
- ក្រុមទី៣ : អាន និងពិភាក្សាអំពី “ស្ថានភាពនៅក្នុងមន្ទីរស-២១” នៅទំព័រទី៦២ ។
- ក្រុមទី៤ : អាន និងពិភាក្សាអំពី “ការសួរចម្លើយ” នៅទំព័រទី៦៣ ។
- ក្រុមទី៥ : អាន និងពិភាក្សាអំពី “ថ្នាក់ដឹកនាំមន្ទីរស-២១” នៅទំព័រទី៦៧ ។
- ក្រុមទី៦ : អាន និងពិភាក្សាអំពី “ការសម្លាប់នៅមន្ទីរស-២១” នៅទំព័រទី៦៨ ។

ចំរើន បានឲ្យក្រុមនីមួយៗអាន និងកត់ត្រានូវចំណុចសំខាន់ៗចំនួនបួន ឬប្រាំចេញពីប្រធានបទនីមួយៗ ដើម្បីចែករំលែក និងពិភាក្សាបន្ទាប់ពីបញ្ចប់ការអាន ។ ក្រុមនីមួយៗមានរយៈពេល៧នាទីក្នុងការបំពេញកិច្ចការនេះ ។ បន្ទាប់ពីអានរួច ចំរើន បានឲ្យតំណាងក្រុមនីមួយៗចែករំលែកការយល់ដឹងរបស់ខ្លួនទៅកាន់ក្រុមផ្សេងទៀតដែលអានប្រធានបទខុសគ្នា ។

### ក្រុមទី១

ស៊ឹម គឹមសាង មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លែង បានធ្វើការសង្ខេបប្រធានបទទី១និយាយអំពី

*“អគារនៅមន្ទីរស-២១” ។*

*“មន្ទីរស-២១ គឺជាអតីតវិទ្យាល័យចៅពញាយ៉ាត ដែលបានសាងសង់ឡើងនៅក្នុងឆ្នាំ១៩៦២ក្នុងបរិវេណដី៦០០ម៉ែត្រគុណនឹង៤០០ម៉ែត្រ ។ មានអគារសំខាន់ៗចំនួនបួន ។ បន្ទប់នៅជាន់ផ្ទាល់ដី ត្រូវបានបែងចែកជាបន្ទប់តូចៗសម្រាប់ឃុំឃាំងអ្នកទោសម្នាក់ៗ ដែលមានទំហំ០.៨ម៉ែត្រគុណនឹង២ម៉ែត្រ ។ បន្ទប់នៅជាន់ទី១ត្រូវបានប្រើប្រាស់សម្រាប់ឃុំឃាំងអ្នកទោសរួមដែលមានចំនួនពី៤០-៥០នាក់ ។ បន្ទប់ចំនួនមួយ ត្រូវបានប្រើប្រាស់ធ្វើជាការិយាល័យរបស់ ឌុច ហើយបន្ទប់ផ្សេងៗទៀតត្រូវបានប្រើប្រាស់សម្រាប់ដាក់ឯកសារ ។ ចំណែកផ្ទះដែលនៅក្បែរៗមន្ទីរ ត្រូវបានប្រើប្រាស់ជាបន្ទប់សួរចម្លើយ និងធ្វើទារុណកម្ម” ។*

ត្រង់ចំណុចនេះ មុនពេលឈានដល់ការឡើងបង្ហាញរបស់ក្រុមបន្ទាប់ទៀត បូលី បានឲ្យអ្នកចូលរួមទាំងអស់យកប៊ិច និងបើកសៀវភៅមេរៀនត្រង់ទំព័រ៦០ ដើម្បីធ្វើការកែតម្រូវកំហុសឆ្គងមួយ ។ បូលី បានឲ្យអ្នកចូលរួមទាំងអស់កែពីឃ្លាដើម ៖ *“នៅពីក្រោយរបងសាលានេះ មានអគារធ្វើពីឈើប្រក់ស្បូវពីរខ្នងដែលជាអតីតសាលាបឋមសិក្សាបឹងកេងកង ។ អគារទាំងអស់នេះបង្កើតបានទៅជាមន្ទីរស-២១”* ទៅជា *“នៅពីក្រោយរបងសាលានេះ មានអគារធ្វើពីឈើប្រក់ស្បូវពីរខ្នងដែលជាអតីតសាលាបឋមសិក្សាទួលស្លែង”* វិញ ។

បន្ទាប់មក ចំរើន បានឲ្យក្រុមផ្សេងទៀតឡើងបន្ថែមនូវចំណុចខ្វះចន្លោះ ។ ច្រឹក ប៉េងហ៊ួរ មកពីវិទ្យាល័យហ៊ុន សែន កំពង់លែង បានឡើងបំពេញបន្ថែមប្រធានបទទី១ដូចតទៅ៖

*“មន្ទីរស-២១ មានហ៊ុំព័ទ្ធដោយរបងលួសដែលភ្ជាប់ចរន្តអគ្គិសនី និងសំណាញ់ដែកដើម្បីបញ្ចៀសការលួចរត់ចេញរបស់អ្នកទោស ។ ពុំមានអ្នកទោសណាម្នាក់ពីក្នុងអគារទាំង៤នេះ ត្រូវរត់រួចឡើយ ដោយសារតែមានការយាមកាមតឹងរ៉ឹង” ។*

ចំរើន បានកោតសរសើរចំពោះសេចក្តីក្លាហានរបស់សិស្សពីសកម្មភាពចែករំលែករបស់ពួកគេ ។ ចំរើន បានបន្ថែមថា មានអ្នកទោសប្រមាណ១៤.០០០នាក់បានជាប់នៅក្នុងមន្ទីរស-២១ និងមានតែអ្នកទោសចំនួន១២នាក់ប៉ុណ្ណោះដែលនៅមានជីវិតក្រោយការដួលរលំរបបខ្មែរក្រហម ។

**ក្រុមទី២**

លោក សេង លីរតនៈ ជាគ្រូបង្គោលថ្នាក់ខេត្ត បានជួយ ចំរើន ក្នុងការរៀបចំការពិភាក្សា ។ ប៉េង ណារី ជាសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លែង ដែលតំណាងឲ្យក្រុមទី២ បានឡើងសង្ខេបអំពីប្រធានបទ “អ្នកទោសនៅមន្ទីរស-២១” ដូចតទៅ៖

*“អ្នកទោសភាគច្រើនបានត្រូវចោទប្រកាន់ពីបទក្បត់បក្ស និងអង្គការ ។ អ្នកដឹកនាំ មានការសង្ស័យថាជនក្បត់គឺមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេសកម្ពុជា ។ ជារៀងរាល់ខែ កម្មាភិបាលមកពីតំបន់ផ្សេងៗត្រូវបានចាប់ខ្លួន និងយកមកដាក់ឃុំឃាំងនៅក្នុងមន្ទីរស-២១” ។*

រតនៈ បានលើកទឹកចិត្តអ្នកចូលរួមផ្សេងទៀតឲ្យជួយបំពេញបន្ថែមនូវប្រធានបទទី២ ។ ដោយយល់ឃើញថា សិស្សខ្លះមានការភ័យខ្លាចនៅពេលដែលក្រោកឈរនិយាយទៅកាន់អ្នកចូលរួមទាំងអស់ ។ ចំរើន បានអនុញ្ញាតិឲ្យសិស្សឡើងបង្ហាញពីប្រធានបទរបស់ខ្លួននៅតាមកន្លែងដែលខ្លួនអង្គុយ ។ យុវសិស្សម្នាក់ឈ្មោះ រចនា បានបន្ថែមថា៖

*«ចម្លើយភាគច្រើននៅមន្ទីរស-២១ គឺជាចម្លើយមិនពិត ពីព្រោះអ្នកទោសទាំងនោះមិនបានធ្វើអ្វីដែលខុសនោះទេ ។ អ្នកទោសឆ្លើយ គឺគ្រាន់តែចង់ចៀសវាងការធ្វើទារុណកម្មប៉ុណ្ណោះ» ។*

រតនៈ បានសួរថាតើមានអ្នកទោសជនជាតិវៀតណាមប៉ុន្មាននាក់បានជាប់នៅក្នុងមន្ទីរស-២១? នៅពេលដែលពុំមាននរណាម្នាក់នៅក្នុងក្រុមឡើងឆ្លើយបន្ថែម ចំរើន និងរតនៈ បានបន្តទៅកាន់ក្រុមទី៣ទៀត ។

**ក្រុមទី៣**

ជា ស្រីនាង ជាសិស្សនៅវិទ្យាល័យហ៊ុន សែន កំពង់លែង បានសង្ខេបប្រធានបទទី៣ដែលនិយាយអំពី «ស្ថានភាពនៅក្នុងមន្ទីរស-២១» ដូចតទៅ៖

*«នៅពេលទៅដល់មន្ទីរស-២១ អ្នកទោសទាំងអស់ត្រូវថតរូប និងបំពេញប្រវត្តិរូប ដោយចាប់ផ្តើមពីជីវិតពីកុមារភាពរហូតដល់ពេលត្រូវចាប់ខ្លួន ។ អ្នកទោសទាំងអស់ត្រូវសម្រាតខោអាវចេញពីខ្លួន ហើយវត្ថុដែលនៅជាប់នឹងខ្លួនក៏ត្រូវបានរឹបអូស ។ បន្ទាប់មក អ្នកទោសទាំងអស់ត្រូវដាក់ខ្នោះ និងដាក់នៅក្នុងបន្ទប់ឃុំឃាំង ។ អ្នកទោសមិនត្រូវបានអនុញ្ញាតិឲ្យនិយាយស្តីឡើយ ។ ប្រសិនបើចង់ផឹកទឹក ឬធ្វើអ្វីមួយ អ្នកទោសត្រូវស្នើសុំការអនុញ្ញាតិពីកងសន្តិសុខ បើមិនដូច្នេះទេ អ្នកទោសនឹងត្រូវទទួលទារុណកម្ម» ។*

ស្រីនាង បាននិយាយពីប្រវត្តិរបស់ វ៉ាន់ណាត ថា៖

*«លោក វ៉ាន់ណាត ត្រូវបានដាក់ខ្នោះភ្ជាប់នឹងរនងដែកវែងៗជាមួយអ្នកទោសផ្សេងទៀតប្រហែល ៤០នាក់ ។ អ្នកទោសទទួលរបបអាហារពីរពេលក្នុងមួយថ្ងៃ គឺបបរពីរបីស្លាបព្រា រួមជាមួយសម្លដែលស្ងោរជាមួយស្លឹកឈើ ។ អ្នកទោសទទួលការងូតទឹកជារៀងរាល់បួនថ្ងៃម្តង ។ ប៉ុន្តែប្រសិនបើអ្នកទោសណាដែលជាប់ខ្នោះនៅជិតបង្អួច គឺមិនទទួលបានទឹកសម្រាប់ងូតគ្រប់គ្រាន់ទេ» ។*

ស្រីនាង បានបន្ថែមថា៖

*«ចាប់តាំងពីស្ថានភាពនៅក្នុងមន្ទីរស-២១ក្លាយជាភាពកខ្វក់ អ្នកទោសមួយចំនួនបានកើតស្រែង រមាស និងរៃ ។ ពុំមានពេទ្យសម្រាប់ព្យាបាលជម្ងឺទេ» ។*

រតនៈ បានសួរថា តើកងសន្តិសុខមកពីកងផ្សេងអាចចូលកាន់កន្លែងផ្សេងៗដែលមិនមែនជាភារកិច្ចរបស់អ្នកទាំងនោះបានដែរឬទេ ។ ស្រីនាង បានឆ្លើយតបវិញថា កងសន្តិសុខទាំងនោះមិនត្រូវបានអនុញ្ញាតិឲ្យផ្លាស់ប្តូរពីកន្លែងមួយទៅកាន់កន្លែងមួយទៀតទេ ។

**ក្រុមទី៤**

សិស្សស្រីម្នាក់បានឡើងមកខាងមុខវេទិកា និងបានសង្ខេបពីប្រធានបទ "ការសួរចម្លើយនៅមន្ទីរ ស-២១" ប្រាប់ទៅអ្នកចូលរួមថា៖

"កម្មាភិបាលសួរចម្លើយបានធ្វើទារុណកម្មអ្នកទោសយ៉ាងឃោរឃៅ ។ ពួកគេវាយអ្នកទោសនឹងមែកឈើ ដំបង ឬដោយដៃ ។ អ្នកទោសត្រូវបានឆក់ខ្សែភ្លើង ឬចងរូតចុះឡើងៗ ។ កម្មាភិបាលសួរចម្លើយ បានដកក្រចកអ្នកទោស និងចាក់ទឹកអាល់កុលលើស្នាមរបួសនោះ ។ ពួកគេក៏បានធ្វើទារុណកម្មទៅលើអ្នកទោសស្ត្រីតាមរយៈការកាត់ដោះ និងរំលោភយ៉ាងព្រៃផ្សៃ ទោះជាដឹងថាការរំលោភអ្នកទោសគឺជាការប្រឆាំងនឹងវិន័យរបស់អង្គការក៏ដោយ ។ កងសន្តិសុខដែលត្រូវបានរកឃើញថាបានរំលោភអ្នកទោសស្ត្រី គឺត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។ អ្នកទោសត្រូវបានសួរឲ្យឆ្លើយសារភាពនៅក្នុងប្រវត្តិរូបរបស់ខ្លួនអំពីពេលវេលាដែលខ្លួនបានបម្រើនៅក្នុងជួរបដិវត្តន៍ និងអំពីសកម្មភាពក្បត់របស់ខ្លួន" ។

រតនៈ បានសួរថា តើចម្លើយសារភាពមាននិយាយអំពីសាច់ញាតិ ឬមិត្តភក្រ្តដែរឬទេ? សិស្សនោះបានឆ្លើយថា ចម្លើយសារភាពក៏មានបញ្ជាក់ឈ្មោះមនុស្សដែលចូលរួមក្នុងសកម្មភាពក្បត់ដែរ ។ ឈ្មោះមនុស្សដែលបានបញ្ជាក់នៅក្នុងចម្លើយសារភាព ជាញឹកញាប់គឺជាមិត្តភក្រ្តរបស់ម្ចាស់ចម្លើយសារភាព និងជាឪពុកម្តាយ ។

បំរើន បានសួរបន្ថែមថា តើមានសិស្សណាម្នាក់មកពីក្រុមទី៤ ចង់បន្ថែមព័ត៌មានអ្វីទៀតសដែរឬទេ? រតនៈ ស្នើសុំឲ្យអ្នកចូលរួមអានចំណុចសម្គាល់ចំនួន៥ នៅទំព័រទី៦៤ ដែលនិយាយពីឧទាហរណ៍នៃចម្លើយសារភាពនៅមន្ទីរស-២១ ដោយធ្វើការវិភាគទៅលើចំណុចទាំង៥ ដើម្បីពិចារណាពីស្ថានភាពនៃចម្លើយសារភាពដោយបង្ខំនៅមន្ទីរស-២១ ។ រតនៈ ក៏បានឲ្យអ្នកចូលរួមរំឭកឡើងវិញពីឧទាហរណ៍ផ្សេងទៀតនៃចម្លើយសារភាពដែលមាននៅក្នុងទំព័រទី៦៥ ។

**ក្រុមទី៥**

ក្រុមទី៥ អាន "ថ្នាក់ដឹកនាំនៅមន្ទីរស-២១" ។ សិស្សស្រីម្នាក់ឡើងសង្ខេបដូចខាងក្រោម៖

"មន្ទីរស-២១ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ ដែលដឹកនាំដោយ សុន សេន ហៅ សមមិត្ត ខៀវ ។ គាត់ធ្លាប់បានសិក្សានៅប្រទេសបារាំង និងក្រោយមកគាត់បានក្លាយជាគ្រូបង្រៀន ។ មេដឹកនាំជាន់ខ្ពស់នៅមន្ទីរស-២១រួមមាន ឌុច ជាប្រធាន និង ឃឹម វ៉ាត, ប៉េង និង ចាន់ ជាអនុប្រធាន ។ ប៉ុន គឺជាអ្នកសួរចម្លើយ ។ មេដឹកនាំទាំងនេះ គឺជាអតីតគ្រូបង្រៀន" ។

បំរើន បានសួរថា តើអ្នកចូលរួមទាំងអស់បានឮពីអ្វីដែលសមាជិកនៃក្រុមទី៥ ឡើងធ្វើការសង្ខេបនេះដែរឬទេ និងថាតើក្រុមផ្សេងទៀតមានអ្វីចង់បន្ថែមដែរឬទេ? បំរើន បានបញ្ជាក់ថា សមាជិកនៅក្នុងក្រុមផ្សេងទៀតអាចបន្ថែមព័ត៌មានទៅលើប្រធានបទនេះបាន ។ រតនៈ បានទាញការយកចិត្តទុកដាក់របស់អ្នកចូលរួមដោយបង្ហាញពីតួនាទីរបស់ ប៉ុន នៅក្នុងអង្គភាពសួរចម្លើយថា គឺជាអ្នកសួរចម្លើយអ្នកទោសសំខាន់ៗដូចជា

កែវ មាស, ណៃ សារ៉ាន់, ហ៊ូ នឹម, ទីវ អុល និងភោគ ឆាយ ។ រតនៈ បានបញ្ជាក់បន្ថែមថា កម្មាភិបាលខ្មែរក្រហម មិនត្រឹមតែសួរចម្លើយប្រជាជនធម្មតានោះទេ ប៉ុន្តែក៏បានសួរចម្លើយទៅលើកម្មាភិបាលដែលត្រូវបានចោទប្រកាន់ពីបទក្បត់បដិវត្តន៍ដែរ ។

**ក្រុមទី៦**

ព្រះសង្ឃដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបកាលពីថ្ងៃដំបូងនៅក្នុងបរិវេណវត្តបានអានចំណុចទី៧នៃមេរៀនដែលនិយាយអំពី«ការសម្លាប់នៅមន្ទីរស-២១» ចែកជូនដល់អ្នកចូលរួមស្តាប់ ។

រតនៈ បានពន្យល់ដល់អ្នកចូលរួមទាំងអស់ពីពាក្យ «កម្ទេច» ដែលកម្មាភិបាលខ្មែរក្រហមបានប្រើជំនួសឲ្យពាក្យ «សម្លាប់» ។ រតនៈ បានបន្ថែមថាចម្លើយសារភាពនៅក្នុងមន្ទីរស-២១ ជួនកាលមានរហូតដល់ទៅរាប់រយទំព័រ ។ ខ្មែរក្រហមមិនបានយកចិត្តទុកដាក់ពីស្ថានភាពរបស់អ្នកទោសឡើយ ។ ប៉ុន្តែពួកគេយកចិត្តទុកដាក់តែពីចម្លើយសារភាពដែលកត់ត្រាពីអ្វីដែលខ្លួនត្រូវការ ។ នៅឆ្នាំដំបូងនៃប្រតិបត្តិការរបស់មន្ទីរស-២១ សាកសពទាំងអស់ត្រូវបានកប់នៅក្បែរនោះ ។ នៅឆ្នាំ១៩៧៦ បន្ទាប់ពីលែងមានកន្លែងសម្រាប់កប់ខ្មោចអ្នកទោសត្រូវបានបញ្ជូនទៅកាន់បឹងជើងឯក ដែលមានចម្ងាយប្រមាណ១៣គីឡូម៉ែត្រពីភ្នំពេញ ។ បឹងជើងឯកគឺត្រូវបានកំណត់ថាជាទីតាំងប្រវត្តិសាស្ត្រដែលជីវិតមនុស្សរាប់សិបនាក់ត្រូវបានសម្លាប់នៅទីនោះ ។ រតនៈ បានចែករំលែកបទពិសោធន៍របស់គាត់ដែលបានចូលទៅទស្សនានៅជើងឯក ក្រោមការឧបត្ថម្ភរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

បន្ទាប់ពីអ្នកចូលរួមទាំងអស់ពិភាក្សាលើចំណុចទាំង៦រួចហើយ ចំរើន បានធ្វើការសង្ខេបទៅលើជំពូកទាំងមូលម្តងទៀត ។ បន្ទាប់មក ចំរើន បានសួរសំណួរស្វែងយល់មួយចំនួន ដើម្បីវាស់ស្ទង់ការយល់ដឹងរបស់អ្នកចូលរួមពីជំពូកនេះ មុនពេលដែលអនុញ្ញាតិឲ្យគាត់សួរសំណួរ ។

## ៣) សំណួរពីអ្នកចូលរួម

នៅចុងបញ្ចប់នៃការធ្វើវេទិកានេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកទឹកចិត្តដល់អ្នកចូលរួមឲ្យសួរសំណួរដែលមានរយៈពេលត្រឹមតែ២០នាទី ។

១) សូ វិសាល ជាសិស្សមកពីវិទ្យាល័យ ហ៊ុនសែន កំពង់លែង៖ «តើខ្មែរក្រហមបានទទួលអាវុធយុទ្ធភណ្ឌមកពីណា?

២) វ៉ាន់ ស្រីល័ក្ខ ជាសិស្សមកពីវិទ្យាល័យ ហ៊ុនសែន កំពង់លែង៖ «តើមនុស្សប្រភេទណាជាកម្មាភិបាលខ្មែរក្រហម? ហេតុអ្វីបានជាកម្មាភិបាលខ្មែរក្រហមទាំងនោះសម្លាប់មនុស្ស?»

៣) សួន សីហា ជាសិស្សមកពីវិទ្យាល័យ ហ៊ុនសែន កំពង់លែង៖ «នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានបញ្ជាក់ថា គណៈប្រតិភូបរទេសបានមកទស្សនាប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តើគណៈប្រតិភូទាំងនេះជាបនក្បត់ឬ? តើអ្នកទាំងនោះបានដឹងពី

ស្ថានភាព និងនយោបាយរបស់ខ្មែរក្រហមឬទេ? ហេតុអ្វីបានជាបញ្ញវន្តត្រូវនាំយកទៅសម្លាប់នៅពេលដែលអ្នកមិនចេះដឹងត្រូវបានលើកឲ្យធ្វើជាអ្នកដឹកនាំ?»

៨) វី ស្រីយ៉ា ជាសិស្សមកពីវិទ្យាល័យ ហ៊ុនសែន កំពង់លែង៖ «ហេតុអ្វីបានជាជនជាតិបរទេសត្រូវជាប់ឃុំឃាំងនៅក្នុងមន្ទីរស-២១ដែរ?»

៩) គង់ សុខន ជាសិស្សមកពីវិទ្យាល័យ ហ៊ុនសែន កំពង់លែង៖ «ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅកាន់ទីជនបទ និងបង្ខំឲ្យធ្វើការធ្ងន់? ផលិតផល ត្រូវបាននាំចេញទៅកាន់ប្រទេសចិន ដើម្បីប្តូរមកវិញនូវអាវុធយុទ្ធភណ្ឌ។ ហេតុអ្វីបានជាខ្មែរក្រហមចង់បានអាវុធ? អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានកាត់ទោស ឌុច ឲ្យជាប់គុករយៈពេល៣៥ឆ្នាំ។ តើក្រុមគ្រួសាររបស់ ឌុច ត្រូវបានកាត់ទោសដែរឬទេ?

នៅចុងបញ្ចប់វគ្គសំណួរនិងចម្លើយ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចែក «តារាងស្ទាបស្ទង់មតិក្រោយការធ្វើវេទិកា» ដល់អ្នកចូលរួមបំពេញ ដើម្បីចង់ដឹងថាតើចំណេះដឹង និងការឆ្លើយតបចំពោះការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមានការផ្លាស់ប្តូរយ៉ាងដូចម្តេច បន្ទាប់ពីបានចូលរួមក្នុងវេទិកាសាធារណៈរួចមក។

## លទ្ធផល និងផលប៉ះពាល់

ការស្វែងយល់អំពីប្រវត្តិទីតាំងមុនពេលធ្វើវេទិកាសាធារណៈ បានផ្តល់ឲ្យក្រុមការងារនូវផលចំណេញយ៉ាងសម្បើមទាំងការពិភាក្សា និងទំនាក់ទំនងដល់ការធ្វើវេទិកាសាធារណៈ។ ស្ថិតនៅនឹងទីតាំងផ្ទាល់ ក្រុមការងារបានជួបជាមួយមនុស្សសំខាន់ផ្សេងៗគ្នា ដើម្បីជួយសម្រួលដល់ការរៀបចំធ្វើវេទិកាសាធារណៈនេះ និងស្វែងយល់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗដែលកើតឡើងនៅក្នុងឃុំកំពង់ហៅ និងស្រុកកំពង់លែងទាំងមូល។ ក្រុមការងារបានដឹងថា មានមន្ទីរសន្តិសុខឡាបាន និងបានដឹងទៀតថា វត្តអម្ពវនារាមត្រូវបានខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរសេដ្ឋកិច្ច និងកន្លែងស្តុបស្រូវនិងវត្ថុផ្សេងៗទៀត។ ក្នុងពេលធ្វើវេទិកាសាធារណៈក្រុមការងារបានផ្សារភ្ជាប់ការពិភាក្សានៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ទៅនឹងព្រឹត្តិការណ៍សំខាន់ៗខ្លះទៀតដែលកើតឡើងនៅក្នុងភូមិនេះកាលពីរបបខ្មែរក្រហម។ នេះគឺជាការលើកទឹកចិត្តដល់អ្នកភូមិឲ្យរំឮកឡើងវិញនូវ បទពិសោធន៍ និងចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនជាមួយនឹងកូនចៅរបស់គាត់។ មុនពេលចាប់ផ្តើមវេទិកាសាធារណៈក្រុមការងារបានចាប់អារម្មណ៍ថា អ្នកភូមិដែលមានវ័យចំណាស់មួយចំនួនពុំសូវបានដឹងពីមន្ទីរសន្តិសុខឡាបាន និងពុំសូវបានដឹងថាវត្តអម្ពវនារាម ត្រូវខ្មែរក្រហមប្រើប្រាស់ឡើយ។ បន្ទាប់ពីបញ្ចប់ការធ្វើវេទិកានេះទៅប្រជាជនមួយចំនួន រួមទាំងក្មេងជំនាន់ក្រោយផង បានស្វែងយល់ពីព្រឹត្តិការណ៍សំខាន់ៗ និងរឿងរ៉ាវរបស់អ្នកភូមិរបស់គាត់ឆ្លងកាត់របបខ្មែរក្រហម។ ដោយភ្ជាប់សាច់រឿងរបស់អ្នកភូមិទៅនឹងជំពូក៩ដែលនិយាយពី «គុកទួលស្លែង» សហគមន៍បានរួមបញ្ចូលគ្នា និងធ្វើឲ្យមានទំនាក់ទំនងកាន់តែធំឡើងអំពីបរិបទប្រវត្តិសាស្ត្រខ្មែរក្រហម។

កិច្ចការនេះ បានធ្វើឲ្យអ្នកចូលរួមពង្រីកចំណេះដឹងរបស់ខ្លួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈកិច្ចការដ៏មានសារៈសំខាន់មួយដែលអ្នកទាំងអស់គ្នាអាចនិយាយប្រាប់ពីចំណេះដឹង ឬបទពិសោធន៍ផ្ទាល់ខ្លួនពីមុនរបស់ខ្លួន ។

គ្រូឧទ្ទេសថ្នាក់ខេត្តមិនត្រឹមតែជួយក្រុមការងារក្នុងការរៀបចំ និងចាត់ចែងធ្វើវេទិកាសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចូលរួមនៅក្នុងវេទិកានេះទៀតផង ។ យោងតាមបទពិសោធន៍ដែលធ្លាប់មានកន្លងមក ឃើញថាក្រុមការងារមានភាពងាយស្រួលច្រើន ដោយមានការជួយពីគ្រូឧទ្ទេសថ្នាក់ខេត្តក្នុងការបង្រៀន និងដឹកនាំការពិភាក្សា ។ រតនៈ ដែលជាគ្រូឧទ្ទេសថ្នាក់ខេត្ត បានប្រើប្រាស់ចំណេះដឹង ជំនាញ និងបទពិសោធន៍របស់គាត់ដែលបានមកពីការចូលរួមវគ្គបណ្តុះបណ្តាលកន្លងមក ក្នុងការចែករំលែក និងបង្រៀនដល់អ្នកចូលរួមទាំងអស់ ។ ការចូលរួមជាក្រុមជាមួយគ្រូឧទ្ទេសថ្នាក់ខេត្ត បានបន្ថែមនូវចំណេះដឹង ការទុកចិត្ត និងអារម្មណ៍កក់ក្តៅក្នុងការធ្វើវេទិកាសាធារណៈនេះ ។

ក្រុមការងារបានដឹងថា វិទ្យាល័យគំពង់លែងបានទទួលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតែចំនួនពីរបីក្បាលប៉ុណ្ណោះ ។ គ្រូម្នាក់បាននិយាយថា សិស្សបានចែកវេណគ្នាអានសៀវភៅនេះ ។ ការខ្វះខាតប្រភពធនធាននេះ មិនបានធ្វើឲ្យមានប្រសិទ្ធិភាពដល់ការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនឡើយ ។ វេទិកានេះមិនត្រឹមតែបានផ្តល់ជាសម្ភារៈបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការលើកទឹកចិត្តបន្ថែមទៀតដល់សិស្ស និងគ្រូ ។

ព្រះសង្ឃក៏បានចូលរួមក្នុងការពិភាក្សាជាមួយសិស្សដែរ ។ នៅថ្ងៃដែលក្រុមការងារបានទៅទស្សនាទីតាំងដែលត្រូវធ្វើវេទិកាសាធារណៈ ក្រុមការងារមានឱកាសជួបជាមួយព្រះសង្ឃមួយអង្គដែលកំពុងបង្រៀនសិស្សឲ្យអាន និងសរសេរ ។ ដោយដឹងថាក្រុមការងារបង្កើតវេទិកាសាធារណៈមួយនៅទីនេះ ព្រះអង្គបានបង្ហាញការចាប់អារម្មណ៍ និងស្នើសុំចូលរួមនៅក្នុងវេទិកានេះជាមួយអ្នកភូមិដែរ ។ ក្រុមការងារយើងទទួលស្វាគមន៍ការចូលរួមនេះ និងសុំឲ្យព្រះអង្គជួយនិមន្តព្រះសង្ឃផ្សេងទៀតឲ្យមកចូលរួមដែរ ។ ព្រះសង្ឃចំនួន១៨អង្គបាននិមន្តមកចូលរួមក្នុងថ្ងៃធ្វើវេទិកាសាធារណៈ ។ ព្រះសង្ឃគ្រប់អង្គបានស្តាប់យ៉ាងយកចិត្តទុកដាក់ និងកត់ត្រានូវការធ្វើបទបង្ហាញអំពីជំពូក៩នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ នៅចុងបញ្ចប់ព្រះសង្ឃដែលក្រុមការងារបានជួបកាលពីម្សិលមិញ បានអានចំណុចមួយនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ចែកជូនដល់អ្នកចូលរួមបានស្តាប់ ។

វេទិកានេះ បានបង្កើតឲ្យមានការសន្ទនារវាងគ្រួសារ និងសហគមន៍ ។ បន្ទាប់ពីវេទិកាបានបញ្ចប់ ក្រុមការងារបានហូបអាហារថ្ងៃត្រង់នៅផ្ទះអ្នកភូមិម្នាក់ដែលស្ថិតនៅទល់មុខវត្តអម្ពវនារាម ។ បន្ទាប់មក ក្រុមការងារបានសម្រាកបន្តិចដើម្បីសន្សំកម្លាំងក្នុងការសម្ភាសអ្នកចូលរួមនាពេលរសៀល ។ ក្នុងពេលសម្រាក ក្រុមការងារបានឮអ្នកភូមិពិភាក្សាគ្នាអំពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម ។ អ្នកភូមិម្នាក់បាននិយាយថា គាត់ត្រូវបានស្នើឲ្យទៅដឹកពូជស្រូវយកទៅព្រួសនៅឯស្រែ ។ កម្មាភិបាលខ្មែរក្រហមបានប្រើគាត់ឲ្យផលិតជីធម្មជាតិដែលធ្វើពី

លាមកគោនិងដើមរុក្ខជាតិ និងលើកទំនប់ ។ អ្នកភូមិម្នាក់ទៀតបានបន្ថែមថា ឪពុករបស់គាត់ត្រូវកម្មាភិបាលខ្មែរក្រហមចាក់ទឹកបញ្ចូលក្នុងសាច់ ដែលជាហេតុធ្វើឲ្យគាត់ស្លាប់ភ្លាមមួយរំពេច ។ គាត់ក៏បានបន្ថែមទៀតថា ប្អូនប្រុសរបស់គាត់ម្នាក់ទៀត បានលួចប៉េងប៉ោះហូបដោយសារឃ្លានពេក ។ ខ្មែរក្រហមបានចាប់ប្អូនរបស់គាត់រួចវាយនៅចំពោះមុខគាត់ ។ គាត់យំ ប៉ុន្តែមិនអាចធ្វើអ្វីបានឡើយដើម្បីជួយប្អូនប្រុស ។ ទីបញ្ចប់ ប្អូនប្រុសរបស់គាត់បានស្លាប់ដោយសារការវាយធ្វើបាបនេះ ។ អ្នកភូមិម្នាក់ផ្សេងទៀតបាននិយាយថា ឪពុករបស់គាត់ជាអតីតពេទ្យទាហានកាលពីជំនាន់លន់ នល់ ។ នៅក្នុងរបបខ្មែរក្រហម ឪពុករបស់គាត់បានចូលរួមប្រជុំជារៀងរាល់ថ្ងៃបន្ទាប់ពីធ្វើការរួច ។ ដោយអស់កម្លាំងខ្លាំងពេក ឪពុករបស់គាត់បានសំរានលក់ទាំងបើកភ្នែកនៅពេលដែលអង្គុយប្រជុំ ។ បន្ទាប់ពីការពិភាក្សាពីជីវិតរបស់ពួកគាត់ក្នុងរបបខ្មែរក្រហម គាត់បានបន្តការពិភាក្សាពីដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទៀត ។ ពួកគាត់បានសំដែងការគាំទ្រចំពោះការងាររបស់តុលាការ និងចង់ឃើញមេដឹកនាំខ្មែរក្រហមទាំងអស់ត្រូវបានកាត់ទោសកាន់តែឆាប់ ។

ក្នុងពេលធ្វើកិច្ចសម្ភាសន៍ជាមួយ បូ ណាវី ក្រុមការងារយើងបានដឹងថាមន្ត្រីរាជការថ្នាក់ឃុំ និងស្រុកក៏ដូចជាគ្រូបង្រៀន ចូលចិត្តអានទស្សនាវដ្តី «ស្វែងរកការពិត» ។ បូ ណាវី បាននិយាយថា គាត់ចូលចិត្តអានទស្សនាវដ្តីនេះណាស់ ព្រោះគាត់ចង់ដឹងឲ្យកាន់តែច្រើនអំពីការស្រាវជ្រាវ និងការអភិវឌ្ឍន៍ថ្មីៗ ។ ស្តាប់ពីការសន្ទនារបស់យើង កូនប្រុសរបស់គាត់ដែលអង្គុយនៅក្បែរនោះបាននិយាយដូច្នេះថា «ម៉ែ! ពុកមាន[ទស្សនាវដ្តីស្វែងរកការពិត] តែមួយច្បាប់ទេ ។ គាត់កាន់វាជាប់រាល់ថ្ងៃ» ។ ណាវី បានប្រាប់ថា គាត់មិនទាន់បានទទួលទស្សនាវដ្តីលេខថ្មីនៅឡើយទេ ។ គាត់បានស្នើសុំឲ្យមានការបញ្ជូនទស្សនាវដ្តីនេះដល់ស្រុករបស់គាត់ឲ្យបានទៀងទាត់ពេលវេលា ។

ក្នុងពេលមានការពិភាក្សាមួយនៅក្នុងទីកន្លែងធ្វើវេទិកា យើងបានស្វែងយល់ថា មន្ទីរសន្តិសុខឡាបានជាមន្ទីរសន្តិសុខមួយផ្សេងទៀតដែលអ្នកទោសមួយចំនួនត្រូវបានបញ្ជូនចូលមកដាក់ឃុំឃាំងនិងសម្លាប់ចោល ។ ក្រុមស្រាវជ្រាវធ្វើដែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពុំទាន់បានមកស្រាវជ្រាវនៅទីតាំងនេះនៅឡើយទេ ដោយសារតែបញ្ហាសន្តិសុខ ។ យោងតាមរបាយការណ៍ដែលបានសរសេរដោយក្រុមស្រាវជ្រាវរណ្តៅសាកសពនេះបានឲ្យដឹងថា ក្រុមការងារមិនអាចស្នាក់នៅក្នុងទីរួមស្រុកកំពង់លែងបានឡើយ ហើយត្រូវតែធ្វើដំណើរត្រឡប់មកកាន់ទីរួមខេត្តវិញនៅវេលាម៉ោង៣ ឬ៤រសៀល ដោយសារមូលហេតុពីរយ៉ាងគឺៈ ១) ដើម្បីចៀសវាងភាពងងឹតដែលជាពេលវេលារបស់ក្រុមខ្មាំងខ្មែរក្រហមចូលមកក្នុងភូមិ និង ២) ដើម្បីចៀសវាងខ្យល់ព្យុះដែលធ្វើឲ្យលិចទូក ។ ក្នុងរបាយការណ៍ដដែលបានផ្តល់យោបល់ថា ក្រុមការងារបានបង្កើតការស្រាវជ្រាវបន្ថែមទៀតទៅលើមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ដែលមាននៅក្នុងកន្លែងផ្សេងៗក្នុងស្រុកកំពង់លែង និងជាកន្លែងដែលមិនទាន់បានធ្វើការស្រាវជ្រាវ ។ ការរកឃើញថ្មីនេះ អាចដាក់បញ្ចូលទៅក្នុងចំនួនមន្ទីរសន្តិសុខដែលក្រុមស្រាវជ្រាវបានកត់ត្រាទុករួចហើយនៅក្នុងដែនទីរណ្តៅសាកសព ។

## បញ្ហាប្រឈម

ការវាយតម្លៃដែលត្រូវបានធ្វើឡើងនៅចុងបញ្ចប់នៃការធ្វើវេទិកាសាធារណៈ បានចំណាយពេលអស់មួយភាគបីនៃពេលវេលាទាំងអស់ ។ យើងមានតារាងវាយតម្លៃចំនួនពីរគឺ តារាងវាយតម្លៃមុនពេលធ្វើវេទិកា និង តារាងវាយតម្លៃក្រោយពេលធ្វើវេទិកា ។ តារាងវាយតម្លៃនីមួយៗត្រូវចំណាយពេលអស់រយៈពេលប្រហែលកន្លះម៉ោងក្នុងការបំពេញ ។ ដូច្នេះក្នុងការបំពេញតារាងទាំងពីរប្រភេទនេះ គឺត្រូវចំណាយពេលអស់មួយម៉ោងក្នុងចំណោមរយៈពេលបីម៉ោងនៃការធ្វើវេទិកា ។ អ្នកភូមិវ័យចំណាស់ៗដែលពុំអាចសរសេរ និង អានបាន បានពឹងផ្អែកទាំងស្រុងមកលើក្រុមការងារ ។ ក្រុមការងារបានចុះជួយគាត់ម្នាក់ៗក្នុងការបំពេញតារាងស្ទាប់ស្ទង់មតិ ដែលកិច្ចការនេះបានចំណាយពេលវេលាអស់យ៉ាងច្រើន ។ ការស្ទាបស្ទង់មតិមុនពេលធ្វើវេទិកាបានធ្វើឲ្យអង្គវេទិកាទាំងមូលបាត់បង់នូវការចាប់អារម្មណ៍ ។ ដូច្នេះការធ្វើវេទិកាសាធារណៈលើកក្រោយៗទៀតក្រុមការងារត្រូវតែរកវិធីសាស្ត្រផ្សេងក្នុងការបំពេញតារាងស្ទាបស្ទង់មតិ ។

លើសពីនេះទៀត ក្រុមការងារបានចំណាយពេលយ៉ាងច្រើនលើកិច្ចការរដ្ឋបាល និងការធ្វើបទបង្ហាញ ។ ឧទាហរណ៍ លោកតំណាងក្រុមប្រឹក្សាឃុំបានចំណាយពេលនិយាយអស់ប្រហែល២០នាទី ហើយការនិយាយនេះបានធ្វើឲ្យវត្តមានរបស់អ្នកចូលរួមដែលកំពុងរង់ចាំការចាប់ផ្តើមវេទិកា មានការថយចុះ ។ សម្រាប់ការធ្វើអង្គវេទិកាលើកក្រោយ ក្រុមការងារត្រូវតែរំឭកដល់តំណាងក្រុមប្រឹក្សាឃុំជាដំបូងអំពីគោលបំណង និងទំហំនៃការនិយាយរបស់គាត់ ។ សេចក្តីថ្លែងការរបស់គាត់ គួរតែត្រូវបានផ្តោតជាសំខាន់ទៅលើការសិក្សាពីអំពើប្រល័យពូជសាសន៍ ។

នៅពេលដែលនិយាយទៅកាន់អ្នកចូលរួម ក្រុមការងារបាននិយាយសំដៅតែទៅលើសិស្សានុសិស្សហើយមិនសូវអើពើចំពោះវត្តមានរបស់អ្នកភូមិនិងគ្រូបង្រៀន ដែលជាហេតុធ្វើឲ្យគាត់មានអារម្មណ៍មិនសូវកក់ក្តៅ និងមិនស្ថិតនៅក្នុងកន្លែងប្រជុំ ។ ការនិយាយទៅកាន់អ្នកចូលរួម គឺសំខាន់ណាស់ក្នុងការធ្វើឲ្យមានភាពស្មើគ្នា ។ ក្រុមការងារបានសង្កេតឃើញថាព្រះសង្ឃនិងអ្នកភូមិខ្លះបានចាកចេញពីកន្លែងប្រជុំនៅពាក់កណ្តាលម៉ោង ។ នៅចុងបញ្ចប់ មានតែអ្នកភូមិពីរបីនាក់ប៉ុណ្ណោះដែលនៅអង្គុយរហូតដល់ចប់កម្មវិធី ហើយព្រះសង្ឃបានចាកចេញពីកន្លែងប្រជុំទាំងអស់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមការងារនៅតែប្រារព្ធធ្វើអង្គប្រជុំជាធម្មតានៅក្នុងព្រះវិហារនេះ ។ ទីអារាម គឺជាកន្លែងដែលគ្មានជម្លោះ និងមិនបម្រើឲ្យនយោបាយ ។ តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ការរៀបចំការអង្គុយគួរតែត្រូវធ្វើឡើងសម្រាប់ព្រះសង្ឃ ពីព្រោះព្រះសង្ឃត្រូវតែគង់នៅផ្នែកខាងលើ ។ ក្រុមការងារមិនបានចាប់អារម្មណ៍ពីចំណុចនេះឡើយ ដែលធ្វើឲ្យមានការអាក់អន់ចិត្តពីព្រះសង្ឃថាយើងមិនបានគោរពដល់សាសនា ។ បន្ទាប់ពីបានដឹងពីកំហុសឆ្គងនេះ ក្រុមការងារបានរៀបចំកន្លែងសម្រាប់ព្រះសង្ឃគង់ភ្លាមៗ ។

**សមាជិកក្រុមការងារ៖**

ឌី ឍាំបូលី

ផេង ពង្សរ៉ាស៊ី

ប្រាក់ កែវ តារា

លី សុខចំរើន